បទប្បញ្ញត្តិច្បាប់ទាំងនេះ គ្របដណ្តប់លើគ្រប់និយោជិតទាំងអស់ដែលបម្រើការងារនៅក្នុងដែនកំណត់របស់ទីក្រុង SEATTLE ដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់និយោជិត ឬទីកន្លែងនិយោជកររបស់ពួកគេនោះទេ។ និយោជកត្រូវអនុវត្តតាមច្បាប់ទាំងអស់នេះ។ ការសងសឹក គឺជាអំពើខុសច្បាប់។

# បទប្បញ្ញត្តិច្បាប់ស្តង់ដារការងារទីក្រុង Seattle ឆ្នាំ 2026

បេសកកម្មនៃការិយាល័យស្តង់ដារការងារ (Office of Labor Standards) គឺធ្វើឲ្យមានភាពប្រសើរឡើងនៃស្តង់ដារការងារតាមរយៈការចូលរួមផ្នែកអាជីវកម្ម និងសហគមន៍ដែលមានការគិតគូរបានដិតដល់ ការបង្កើតគោលនយោបាយដែលមានការច្នៃប្រឌិត និងការពង្រឹងការអនុវត្តច្បាប់ជាយុទ្ធសាស្ត្រ ជាមួយនឹងការប្តេជ្ញាចិត្តធ្វើឲ្យមានយុត្តិធម៌ផ្នែកជាតិសាសន៍ និងសង្គម។

ផ្ទាំងផូស្ទ័រនេះ ត្រូវដាក់តាំងបង្ហាញនៅកន្លែងដែលងាយស្រួលកត់សម្គាល់នៅកន្លែងធ្វើការជាភាសាអង់គ្លេស និងភាសា(ផ្សេងៗ) ដែលនិយោជិតនិយាយនៅកន្លែងធ្វើការ។

ការិយាល័យស្តង់ដារការងារ ផ្តល់ជូននូវការបកប្រែឯកសារ ការបកប្រែផ្ទាល់មាត់ និងកន្លែងស្នាក់នៅសម្រាប់ជនដែលមានពិការភាព។

## ប្រាក់ឈ្នួលអប្បបរមា

### កំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់និយោជិត

**និយោជកទាំងអស់**
**មិនថាមានទំហំប៉ុនណាត្រូវតែចំណាយយ៉ាងតិច**

# $21.30

**ក្នុងមួយម៉ោង**

គ្មាននិយោជិតណាអាចយកប្រាក់ទូទាត់ថ្លៃអត្ថប្រយោជន៍ខាងវេជ្ជសាស្ត្រសម្រាប់និយោជិត ឬលុយធីបដែលអតិថិជនបានផ្តល់ឱ្យនិយោជិត ទៅបង្គ្រប់ចំណែកណាមួយនៃប្រាក់ឈ្នួលអប្បបរមានោះទេ។

**ប្រាក់ឈ្នួលអប្បបរមារបស់ទីក្រុង Seattle កើនឡើងរាល់ឆ្នាំប្រតិទិន** ដោយផ្អែកតាមអត្រាអតិផរណា។ ប្រាក់ឈ្នួលអប្បបរមាថ្មីចាប់ផ្តើមប្រសិទ្ធភាពនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ ការិយាល័យស្តង់ដារការងារ (Office of Labor Standards) ប្រកាសអំពីប្រាក់ឈ្នួលអប្បបរមាថ្មីនៅរាល់រដូវស្លឹកឈើជ្រុះ។

## ការសម្រាកព្យាបាលជំងឺដែលទទួលបានប្រាក់កម្រៃនិងពេលវេលាសុវត្ថិភាព

### តម្រូវឲ្យមានច្បាប់ឈប់សម្រាកដែលទទួលបានប្រាក់កម្រៃសម្រាប់បញ្ហាសុខភាពឬសុវត្ថិភាព

**និយោជក ត្រូវផ្តល់ច្បាប់ឈប់សម្រាកដែលទទួលបានប្រាក់កម្រៃទៅឲ្យនិយោជិត ដើម្បីមើលថែទាំខ្លួនពួកគេផ្ទាល់ ឬសមាជិកគ្រួសារ។**

(កុមារ ឪពុក/ម្តាយ ប្តីប្រពន្ធ ដៃគូរស់នៅជាមួយគ្នាដែលបានចុះបញ្ជី ជីដូន/ជីតា ចៅ បងប្អូន)

**ពេលមានជំងឺ៖** លក្ខខណ្ឌសុខភាពផ្លូវចិត្តនិងផ្លូវកាយ រួមមានការណាត់ជួបគ្រូពេទ្យជាដើម

**ពេលវេលាសុវត្ថិភាព៖** មូលហេតុដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ការឃ្លាំមើលក្នុងចេតនាមិនល្អឬបញ្ហាសុខភាពសាធារណៈ*

**អត្រាប្រាក់ឈ្នួលនៃច្បាប់ឈប់សម្រាកព្យាបាលជំងឺដែលទទួលបានប្រាក់កម្រៃ និងពេលវេលាសុវត្ថិភាព (PSST)**

| | ថ្នាក់ទី 1 | ថ្នាក់ទី 2 | ថ្នាក់ទី 3 |
|---|---|---|---|
| **ទំហំនិយោជក** និយោជិតធ្វើការដូចអ្នកធ្វើការពេញម៉ោង (FTEs) នៅទូទាំងពិភពលោក | រហូតដល់ទៅ **49** FTEs | **50 – 249** FTEs | **250+** FTEs |
| **ចំនួនបង្គរនៃ PSST** ក្នុងចំនួនម៉ោងដែលបានធ្វើការ | **1 ម៉ោង** ក្នុង 40 ម៉ោង | **1 ម៉ោង** ក្នុង 40 ម៉ោង | **1 ម៉ោង** ក្នុង 30 ម៉ោង |
| **ចំនួន PSST លើកបន្តដែលមិនទាន់បានប្រើប្រាស់** ក្នុងមួយឆ្នាំ | **40 ម៉ោង** | **56 ម៉ោង** | **72 ម៉ោង**** |

*ពេលវេលាសុវត្ថិភាពក៏អាចប្រើប្រាស់បានផងដែរសម្រាប់សមាជិកគ្រួសារ

**108 ម៉ោងសម្រាប់និយោជកថ្នាក់ទី 3 ដែលមានគោលនយោបាយឈប់សម្រាកដោយទទួលបានប្រាក់កម្រៃ (PTO)

## ការជ្រើសបុគ្គលិកឲ្យចូលបម្រើការងារដោយទទួលបានឱកាសស្មើគ្នា

### កំណត់ការប្រើប្រាស់កំណត់ត្រា

**បម្រាម៖**

- ការផ្សាព្វផ្សាយការងារដែលមិនរួមបញ្ចូលអ្នកដាក់ពាក្យស្នើសុំដែលមានប្រវត្តិជាប់ទោសនិងធ្លាប់បានចាប់ខ្លួន
- ការដាក់ពាក្យសុំការងារដែលមានសំណួរអំពីប្រវត្តិនៃការជាប់ ទោសនិងការចាប់ខ្លួន លើកលែងតែនិយោជកបានត្រួតពិនិត្យអ្នកដាក់សុំការងារសម្រាប់លក្ខណៈសម្បត្តិអប្បបរមា
- ការបដិសេធការងារ (ឬវិធានការធ្ងន់ធ្ងរដទៃផ្សេងទៀតផ្នែកការងារ) ផ្អែកទាំងស្រុងលើកំណត់ត្រានៃការចាំខ្លួន

មានករណីលើកលែងមួយចំនួន ដូចជាការងារនានាដែលមិនមានការត្រួតពិនិត្យលើការប្រើប្រាស់កុមារក្រោមអាយុ 16 ឆ្នាំអ្នកដែលមានពិការភាពផ្នែកលូតលាស់ ឬមនុស្សពេញវ័យដែលងាយរងគ្រោះជាដើម

**និយោជក ត្រូវបានគេតម្រូវឲ្យ៖**

ពន្យារការត្រួតពិនិត្យមើលសាវតាបទឧក្រិដ្ឋរហូតដល់ក្រោយការត្រួតពិនិត្យអ្នកដាក់សុំការងារសម្រាប់លក្ខណៈសម្បត្តិអប្បបរមារួចរាល់

អនុវត្តតាមនីតិវិធីនានាមុនពេលចាត់វិធានការធ្ងន់ធ្ងរ ដោយផ្អែកទាំងស្រុងទៅតាមការត្រួតពិនិត្យសាវតាបទឧក្រិដ្ឋ៖

» ផ្តល់នូវឱកាសក្នុងការពន្យល់ ឬធ្វើការកែតម្រូវព័ត៌មានត្រួតពិនិត្យសាវតាបទឧក្រិដ្ឋ

» រក្សាទុកមុខតំណែងឲ្យនៅទំនេរយ៉ាងតិចពីរថ្ងៃធ្វើការ

» មានមូលហេតុអាជីវកម្មស្របច្បាប់ដែលបង្ហាញថាការជ្រើសរើសបុគ្គលនោះឲ្យចូលបម្រើការនឹងធ្វើឲ្យប៉ះពាល់ដល់អាជីវកម្ម ឬប៉ះពាល់ដល់សមត្ថភាពរបស់និយោជិតក្នុងបំពេញការងារ

## ការលួចប្រាក់ឈ្នួល

### ផ្តល់នូវការការពារប្រឆាំងនឹងប្រាក់ឈ្នួលបាត់បង់

**និយោជកត្រូវ បង់ថ្លៃសំណងការខូចខាតទាំងអស់ដែលជំពាក់ក្នុងថ្ងៃទូទាត់ប្រាក់ជាទៀតទាត់ និងប្រគល់ជូននូវព័ត៌មានជាលាយលក្ខណ៍អក្សរដល់និយោជិតអំពីការងារនិងប្រាក់ឈ្នួលរបស់ពួកគេ។**

**ព័ត៌មានជាលាយលក្ខណ៍អក្សរ ត្រូវរួមបញ្ចូលនូវ៖**

- ឈ្មោះនិងព័ត៌មានទំនាក់ទំនងរបស់និយោជក
- អត្រានៃប្រាក់ឈ្នួលរបស់និយោជិក សិទ្ធិទទួលបានការរកប្រាក់ចំណូលម៉ោងបន្ថែម មូលដ្ឋា ននៃការបើកប្រាក់ (គិតជាម៉ោង តាមវេន ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬប្រាក់កម្រៃជើងសារ) និងការបង់ប្រាក់ប្រចាំថ្ងៃជាប្រចាំ
- ការពន្យល់គោលនយោបាយប្រាក់ទឹកតែរបស់និយោជក
- ធ្វើរបាយការណ៍លម្អិតស្តីពីព័ត៌មានបើកប្រាក់ នៅថ្ងៃបើកប្រាក់

**ឧទាហរណ៍នៃលក្ខខណ្ឌតម្រូវការបើកប្រាក់៖**

- បង់ប្រាក់ឈ្នួលអប្បបរមា
- បង់ប្រាក់ថែមម៉ោង
- បង់ប្រាក់សម្រាប់ពេលវេលាសម្រាកពីការងារ
- បង់ប្រាក់តាមចំនួនដែលបានសន្យា
- បង់ប្រាក់សម្រាប់ការងារក្រៅម៉ោងធ្វើការ
- បង់ប្រាក់ទឹកតែ
- បង់ប្រាក់ថ្លៃសេវា (លើកលែងតែមានចែងនៅលើវិក្កយបត្រទទួលប្រាក់ ឬបញ្ជីដែលមិនត្រូវបង់ទៅនិយោជិតដែលបម្រើការជូនអតិថិជន)
- ការទូទាត់សងលើចំណាយរបស់និយោជក
- ពុំមានកំហុសក្នុងការធ្វើចំណាត់ថ្នាក់និយោជិត

## ការធានារ៉ាប់រងអ្នកធ្វើដំណើរទៅមកពីផ្ទះទៅកន្លែងធ្វើការ

និយោជកដែលមាននិយោជិកចាប់ពី 20 នាក់ ឬច្រើនជាងនេះដែលធ្វើការជាមធ្យម 10 ម៉ោង ឬច្រើនជាងនេះក្នុងមួយសប្តាហ៍ ត្រូវតែផ្តល់ជូនដល់និយោជិក នូវលទ្ធភាពក្នុងការកាត់ថ្លៃចំណាយលើការធ្វើដំណើរសាធារណៈ ឬការជិះរថយន្តរួមគ្នាចេញពីប្រាក់ឈ្នួលដែលអាចជាប់ពន្ធរបស់និយោជិករហូតដល់កម្រិតអតិបរមាដែលត្រូវបានអនុញ្ញាតដោយច្បាប់ពន្ធសហព័ន្ធ។ ដើម្បីបំពេញតាមតម្រូវការនេះ និយោជកអាចផ្តល់ប័ណ្ណជិះរថយន្តជំនួសដែលត្រូវបានឧបត្ថម្ភធនយ៉ាងពេញលេញ ឬដោយផ្នែក។ និយោជកត្រូវផ្តល់អត្ថប្រយោជន៍នេះក្នុងរយៈពេល 60 ថ្ងៃនៃថ្ងៃប្រតិទិនដែលគិតចាប់ពីថ្ងៃនិយោជិកចាប់ផ្តើមការងារ។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

**និយោជិត**
ដាក់បណ្តឹងជាមួយ OLS ឬដាក់បណ្តឹងនៅក្នុងតុលាការ

**និយោជក**
ទទួលបានជំនួយលើការអនុវត្តច្បាប់អនុលោមនិង/ឬទទួលបានការបណ្តុះ បណ្តាល


**206-256-5297**
www.seattle.gov/laborstandards

810 THIRD AVE, SUITE 375
SEATTLE, WA 98104

LABORSTANDARDS@SEATTLE.GOV